

# ថ្ងៃមិនល្អ របស់ លោកគ្រូសាន

All Children Reading - Cambodia

Sou Kimsan

LET'S READ!

letsreadasia.org



«ក្រឹង ក្រឹង ក្រឹង!» សំឡេង
នាឡិការោទ៍ ដាស់លោកគ្រូសាន ឱ្យ
ភ្ញាក់ពីដំណេក។



ម៉ូតូរបស់លោកគ្រូសានបែកកង់។



លោកគ្រូសានបណ្ដើរម៉ូតូ ទៅរកកន្លែង
ជួសជុល។



លោកគ្រូសានហេវណាស់។ គាត់ពិសាមីឆៅមួយកញ្ចប់។



មេឃចាប់ផ្តើមងងឹត។



ស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង។



លោកគ្រូសានមកដល់សាលារៀន។
គាត់បានលាងសម្អាតដៃជើងដែល
ប្រឡាក់ភក់។



លោកគ្រូសានឱ្យសិស្សទាំងអស់ក្រោកឈរ ច្រៀងចម្រៀង«ស្អាតជានិច្ច»។



ថ្ងៃមិនល្អរបស់លោកគ្រូសាន

ការណែនាំបន្ថែមអំពីការប្រើប្រាស់សៀវភៅ សៀវភៅរឿងនេះ បានផលិតឡើងដោយមានភ្ជាប់នូវសកម្មភាពនៅក្នុងទំព័រនីមួយៗ សម្រាប់ឱ្យសិស្សធ្វើសកម្មភាពតាមសាច់រឿង។ នៅក្នុងសកម្មភាពទាំងនោះមានប្រើនូវញាណទាំ៥ និងចលនាផងដែរ។ លោកគ្រូអ្នកគ្រូអាចអានរឿង បន្ទាប់មកសិស្សប្តូរវេនគ្នាដើម្បីធ្វើសកម្មភាព។ អត្ថបទរឿង - «ក្រឹង ក្រឹង ក្រឹង!» សំឡេងនាឡិការោទ៍ ដាស់លោកគ្រូសាន ឱ្យភ្ញាក់ពីដំណេក។ សកម្មភាព - គ្រូឱ្យសិស្សស្តាប់សំឡេងនាឡិការោទ៍ ឬ



ឱ្យសិស្សធ្វើសំឡេងនាឡិការោទ៍ «ក្រឹ
ង ក្រឹង ក្រឹង!» សម្ភារៈដែលត្រូវប្រើ -
សន្លឹកប្រតិទិន នាឡិការោទ៍ ឬកណ្ដឹង
កង់ អត្ថបទរឿង - ម៉ូតូរបស់លោកគ្រូ
សានបែកកង់។ សកម្មភាព - គ្រូផ្ដុំ
ប៉េងប៉ោងពាក់កណ្ដាល និងចងមាត់ឱ្យ
ជិត ហើយឱ្យសិស្សប៉ះប៉េងប៉ោងនោះ។
សម្ភារៈដែលត្រូវប្រើ - សន្លឹកប្រតិទិន
ប៉េងប៉ោង អត្ថបទរឿង - លោកគ្រូសាន
បណ្ដើរម៉ូតូ ទៅរកកន្លែងជួសជុល។
សកម្មភាព - គ្រូឱ្យសិស្សរុញគ្នា ដោយ
យកដៃទល់គ្នា ឬរុញតុ ឬរុញជញ្ជាំង
សម្ភារៈដែលត្រូវប្រើ - គ្មាន អត្ថបទរឿង
- លោកគ្រូសានហេវណាស់។ គាត់



ពិសាមីឆៅមួយកញ្ចប់។ សកម្មភាព
- គ្រូសិស្សញ៉ាំមីកញ្ចប់ (ឆៅ) សម្ភារៈ
ដែលត្រូវប្រើ - មីកញ្ចប់ អត្ថបទរឿង
- មេឃចាប់ផ្ដើមងងឹត។ សកម្មភាព -
គ្រូឱ្យសិស្សយកដៃខ្ទប់ភ្នែក ឬបិទភ្លើង
ឬធ្វើឱ្យបន្ទប់ងងឹត សម្ភារៈដែលត្រូវ
ប្រើ - គ្មាន អត្ថបទរឿង - ស្រាប់តែមាន
ភ្លៀងធ្លាក់យ៉ាងខ្លាំង។ សកម្មភាព - គ្រូ
បាញ់ទឹកដាក់ដៃសិស្ស ដើម្បីឱ្យគេមាន
អារម្មណ៍ត្រជាក់ពេលប៉ះទឹក សម្ភារៈ
ដែលត្រូវប្រើ - ទឹក និងដបទឹក ដែលអា
ចបាញ់សាចលើដៃសិស្ស អត្ថបទរឿង
- លោកគ្រូសានមកដល់សាលារៀន។
គាត់បានលាងសម្អាតដៃជើងដែល



ប្រឡាក់ភក់។ សកម្មភាព - គ្រូឱ្យសិស្ស
ហិតក្លិនសាប៊ូលាងដៃ សម្ភារៈដែលត្រូវ
ប្រើ - សាប៊ូដុំ និងសាប៊ូទឹក ដែលបាន
ក្លិនក្រអូប អត្ថបទរឿង - លោកគ្រូសាន
ឱ្យសិស្សទាំងអស់ក្រោកឈរ ច្រៀង
ចម្រៀង«ស្អាតជានិច្ច»។ សកម្មភាព
- គ្រូឱ្យសិស្សក្រោកឈរ ហើយធ្វើ
ចលនា ឬកាយវិការទៅតាមអត្ថន័យ
នៃបទចម្រៀង សម្ភារៈដែលត្រូវប្រើ -
គ្មាន គោលបំណងក្នុងការប្រើវិធីសាស្ត្រ
នេះ គឺដើម្បីឱ្យកុមារអាចចូលរួមស្តាប់
ការនិទានរឿងទៅតាមកម្រិតសកម្ម
ភាពផ្សេងៗគ្នារបស់ពួកគេ។ សិស្សខ្លះ
អាចចូលរួមពិភាក្សាអំពីគំនិតនៅក្នុង



សាច់រឿង។ សិស្សខ្លះទៀតអានរៀន នូវពាក្យថ្មីៗ និងរៀនពីការប្តូរវេនគ្នាម្តង់ម្នាក់ៗ។ ចំណែកឯសិស្សដទៃទៀតជាពិសេស កុមារខ្សោយសតិបញ្ញាធ្ងន់ធ្ងរ គឺដើម្បីឱ្យពួកគេចេះបង្ហាញទឹកមុខ ឬកាយវិការអំពីវត្ថុដែលពួកគេចូលចិត្ត ឬមិនចូលចិត្ត។សៀវភៅនេះអាចធ្វើឱ្យសិស្សផ្សេងៗទៀត មានភាពសប្បាយរីករាយ និងមានអន្តរសកម្មភាពជាមួយគ្នា ក្នុងការស្តាប់រឿងនិទាន និងធ្វើឱ្យសិស្សទាំងនោះមានការចាប់អារម្មណ៍ជាមួយសៀវភៅ។



រឿងនិទាននេះបង្ហាញពីលោកគ្រូឈ្មោះសាន ដែលបានជួបបញ្ហាមួយចំនួននៅតាមផ្លូវធ្វើដំណើរពីផ្ទះទៅសាលារៀន។ លោកគ្រូសានបានឃើញ ឮ ធុំក្លិន និងប៉ះពាល់វត្ថុផ្សេងៗជាច្រើន តាមរយៈការធ្វើសកម្មភាពរបស់គាត់ តាំងពីការភ្ញាក់ពីដំណេក ការធ្វើដំណើរតាមផ្លូវ និងការទៅដល់ថ្នាក់រៀន។ យើងអាចប្រើសៀវភៅនេះសម្រាប់ មត្តេយ្យសិក្សា និងបឋមសិក្សា ឬអាចប្រើនៅផ្ទះក៏បាន។ យើងបង្កើតសៀវភៅនេះឡើង ដើម្បីឱ្យកុមារទាំងអស់អាចប្រើប្រាស់បាន រួមទាំងកុមារខ្សោយសតិបញ្ញាផងដែរ។ គោលបំណងក្នុងការបង្កើត



សៀវភៅនេះឡើងគឺដើម្បីលើកកម្ពស់
នូវការចូលរួម និងការសិក្សារបស់កុមារ
តាមរយៈការធ្វើសកម្មភាពសប្បាយៗ
នៅអំឡុងពេលនៃការស្តាប់ និងអាន
រឿងនិទាន។

អត្ថបទរឿងដោយ/ Text by All Children Reading-Cambodia (a USAID funded project supporting the Ministry of Education, Youth and Sport) and partners រូបគំនូរដោយ លោក សូ គឹមសាន Illustration by Sou Kimsan រចនាទំព័រដោយ អង្គការស៊ីប៉ា Design by Sipar This work is released under Creative Commons CC BY 4.0

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
ថ្ងៃមិនល្អ របស់លោកគ្រូសាន, author: All Children Reading - Cambodia . illustrator: by Sou Kimsan. Published by All Children Reading - Cambodia, © All Children Reading - Cambodia. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/